ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ: ០២៨ សបវ.ដ.៣

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០០៤

# ប្រកាស

## ស្តីពី

## ការផ្សព្វផ្សាយជាលក្ខណៈពាណិជ្ជកម្ម៖ ឯកជនក្នុង វិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រ

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ៥/សរកម/០៧០៤/០០១ ចុះថ្ងៃទី ១៣-០៧-២០០៤ ដែលប្រកាសអោយប្រើ ច្បាប់ធម្មនុញ្ញបន្ថែម សំរាប់ធានានូវដំណើរការ ជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥-០៧-២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤-០១-៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី ០៣-១១-២០០០ ប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រង លើការប្រកបវិជ្ជាជីវៈ ឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០២០០/០៣៩ ចុះថ្ងៃទី ០១-០២-២០០០ ស្តីពីការបង្កើតគណៈគ្រូពេទ្យ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ-បក ចុះថ្ងៃទី ២២-១០-៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៩៤ អនក្រ-បក ចុះថ្ងៃទី ១១-០៩-០២ ស្តីពីបែបបទនិងល័ក្ខខ័ណ្ឌនៃការអនុញ្ញាតអោយជនបរទេសជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រប្រកបវិជ្ជាជីវៈឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យស្តីពីក្រមសីលធម៌គ្រូពេទ្យលេខ ៦១ អនក្របក ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០០៣
- បានឃើញប្រកាសលេខ ០២០/០១ អបស/មព ចុះថ្ងៃទី ០៧-០៩-០១ របស់ក្រសួងសុខាភិបាលស្តីពីបែបបទនិងល័ក្ខខ័ណ្ឌបច្ចេកទេស ក្នុងការសុំបើក ឬ បិទ សុំកែទ្រង់ទ្រាយ ឬប្តូរទីតាំងនៃសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល

## សំរេច

ប្រការ១.- ការផ្សព្វផ្សាយជាលក្ខណៈពាណិជ្ជកម្ម របស់សេវាឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង



អគារទីស្តីការក្រសួងសុខាភិបាល, លេខ ១៥១-១៥៣ វិថីកម្ពុជាក្រោម ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៤២៦ ០៣៤/៤២៦ ៨៤១ ទូរស័ព្ទ: (៨៥៥-២៣) ៧២២ ៨៧៣

ជំនួយវេជ្ជសាស្ត្រ តាមរយៈ វិទ្យុ-ទូរទស្សន៍-សារពត៌មាន-ទស្សនាវដ្ដី-ព្រឹត្តិបត្រវេជ្ជសាស្ត្រ-ប័ណ្ណប្រកាសរូបភាព- សិក្ខាសាលា- ប្រពន្ធ័អេឡិចត្រូនិច- ខិតប័ណ្ណចែកចាយតាមដងផ្លូវ- ការផ្សព្វផ្សាយពាណិជ្ជកម្មដោយប្រើឧបករណ៍សព្ទតាមទីសាធារណៈ-រថយន្ត-រោងល្ខោន-រោងភាពយន្ត ផ្សារណាត់ ឬតាមរូបភាព ផ្សេង១ត្រូវហាមឃាត់ដាច់ខាត ។

ប្រការ២,- វិជ្ជាជីវវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ ជំនួយវេជ្ជសាស្ត្រ មិនត្រូវបានអនុញ្ញាតអោយយកទៅធ្វើប្រឌិតធ្វើជាមុខជំនួញ ផ្ទាល់ខ្លួនណាមួយឡើយ។ រូបភាពផ្សព្វផ្សាយដោយផ្ទាល់ ឬដោយប្រយោល ដែលបំផ្លើស ខុសការពិត ទាំងអស់ ត្រូវហាមឃាត់ ។

ប្រការ៣,- ហាមឃាត់ការផ្សព្វផ្សាយអំពីរោគសញ្ញាគ្លីនិក នៃជំងឺ និងវិធីព្យាបាលណាមួយ ដែលមានលក្ខណៈបំផ្លើស បោកប្រាស់អតិថិជន ។

ប្រការ៤,- មិនអនុញ្ញាតអោយប្រើប្រាស់ ឈ្មោះមន្ទីរពេទ្យ ឬ គ្លីនិកឯកជន អ្នកឯកទេសល្បី១ ទោះបីជាបរទេសក្ដី ឬ ខ្មែរក្ដី ក្នុងរូបភាព ក្លែងបន្លំសហការជាមួយ ក្នុងទិសដៅឃោសនាផ្សព្វផ្សាយពាណិជ្ជកម្មឡើយ ។

ប្រការ៥,- បន្ទប់ពិគ្រោះព្យាបាលជំងឺ- បន្ទប់ពិគ្រោះព្យាបាលជំងឺមាត់ធ្មេញ- បន្ទប់ព្យាបាលដោយចលនា បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ-បន្ទប់ពិគ្រោះព្យាបាលជំងឺភ្នែក-បន្ទប់សោភ័ណ្ឌសល្យសាស្ត្រ មន្ទីរពិសោធន៍ មន្ទីរព្យាបាលជំងឺមាត់ធ្មេញ-មន្ទីរសំរាកព្យាបាល-មន្ទីរសម្ភព-មន្ទីរពហុព្យាបាល និង មុខវិជ្ជាជីវៈប្រហាក់ប្រហែលផ្សេងទៀត អាចដាក់ពាក្យសុំធ្វើការផ្សព្វផ្សាយ បានលុះត្រាតែ ទីតាំងសេវានោះមាន ច្បាប់អនុញ្ញាត ឬបានចុះលេខបញ្ជិការ ព្រមទាំងមានឡូហ្គោសំគាល់ពីក្រសួង សុខាភិបាល ។

ប្រការ៦,- រាល់ការផ្សព្វផ្សាយក្នុងក្របខណ្ឌវិជ្ជាជីវៈដែលមិនប៉ះពាល់ដល់ក្រមសីលធម៌គ្រូពេទ្យ អាចប្រព្រឹត្តទៅបានលុះត្រាតែមានការអនុញ្ញាតពីក្រសួងសុខាភិបាល។ ម្ចាស់សេវាឯកជន ដែលមានបំណងផ្សព្វផ្សាយត្រូវដាក់ពាក្យស្នើសុំ មកក្រសួងសុខាភិបាល ដោយភ្ជាប់មកជាមួយនូវខ្លឹមសារអត្ថបទ ស្គ្រីបវីដេអូ ឬ កាសែតសោតទស្សន៍ និងរូបភាព ដែលពាក់ព័ន្ធ នឹងការផ្សាយ ក្រោយពីបានឆ្លងកាត់ការត្រួតពិនិត្យ ផ្តល់យោបល់ ជាមុន ពីសំណាក់ក្រុមប្រឹក្សា គណៈវិជ្ជាជីវៈនិមួយ១ នៃខេត្ត-ក្រុង ។

ប្រការ៧,- សេវាឯកជនវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ដែលមានបំណងផ្សព្វផ្សាយ តាមមធ្យោបាយ អ្វីក៏ដោយ ត្រូវប្រើពាក្យពេចន៍ដោយប្រុងប្រយ័ត្ន និង គិតទៅដល់ ប្រតិយាត នៃពាក្យពេចន៍ របស់ខ្លួនចំពោះសាធារណៈជននិងក្រមសីលធម៌គ្រូពេទ្យ ជៀសវាងអំពើឃោសនា លើក



x5

ដំកើងខ្លួន ប្រកួតប្រជែង ដើម្បីផ្តល់រំលំ សេវាកម្មមួយទៀតសំរាប់ មូលហេតុអ្វីមួយ ដែលមិនមែនជាផលប្រយោជន៍សាធារណៈ ។

ប្រការ៨.- ខ្លឹមសារផ្សព្វផ្សាយ ត្រូវមានលក្ខណៈត្រឹមត្រូវ តាមឯកសារវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តសាស្ត្រ និងជៀសវាង ការឃោសនាបំផ្លើសប្រាសចាកខុសពីខ្លឹមសារ ដែលមានការយល់ព្រមអនុញ្ញាត ពីក្រុមប្រឹក្សា គណៈវិជ្ជាជីវនិមួយៗ នៃខេត្ត-ក្រុង និង ពីក្រសួងសុខាភិបាល ។

ប្រការ៩.- អាចអនុញ្ញាតអោយ សុំផ្សព្វផ្សាយបាន គឺ នៅពេលដែលមានការបើកទីតាំងថ្មី ឬ មានការផ្លាស់ប្តូរ ឬ បន្ថែមមុខជំនាញ ផ្លាស់ប្តូរទីតាំង។ អត្ថបទ និងរបៀបផ្សាយត្រូវផ្ញើរទៅក្រុមប្រឹក្សាគណៈវិជ្ជាជីវនិមួយៗ នៃខេត្ត-ក្រុង ពិនិត្យជាមុនសិន ។

ប្រការ១០.- បន្ទាប់ពីបានឆ្លងកាត់ការត្រួតពិនិត្យរួច ក្រសួងសុខាភិបាលអាចអនុញ្ញាតអោយចុះផ្សាយជាសាធារណៈបានគឺ:

១-នាមត្រកូល អាស័យដ្ឋានវិជ្ជាជីវៈ លេខទូរស័ព្ទ និងលេខទូរសារ ថ្ងៃ និងម៉ោងទទួល ពិគ្រោះព្យាបាល ។

២-គុណវុឌ្ឍិ សញ្ញាប័ត្រសិក្សាឯកទេស និងសមត្ថភាពផ្សេងៗ ទទួលស្គាល់ដោយ សាកល វិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និងគណៈវិជ្ជាជីវនិមួយៗ ដែលមានការទទួលស្គាល់ ពីក្រសួងសុខាភិបាល ។

៣-ស្ថានភាពសេវា និងអ្នកផ្តល់សេវា ចំពោះក្រុមហ៊ុនធានារ៉ាប់រង បើមាន ។

៤-ព្រមទាំងខ្លឹមសារផ្សព្វផ្សាយផ្សេងៗទៀត ដែលមានផលប្រយោជន៍ដល់សង្គមជាតិ ។

ប្រការ១១.- រាល់លិខិតអនុញ្ញាតផ្សព្វផ្សាយ តាមគ្រប់រូបភាព មានសុពលភាពរយៈពេល ៦ ខែ គិតចាប់ ពីថ្ងៃចេញលិខិតអនុញ្ញាតពីក្រសួងសុខាភិបាល ។

ប្រការ១២.- ក្រសួងសុខាភិបាលមានសិទ្ធិដកហូតវិញនូវលិខិតអនុញ្ញាតផ្សព្វផ្សាយ ក្នុងករណីពិនិត្យ ឃើញថា :

-ខ្លឹមសារផ្សព្វផ្សាយមានលក្ខណៈខុសពីការយល់ព្រមអនុញ្ញាតរបស់ក្រសួងសុខាភិបាល

-ឬការផ្សព្វផ្សាយនោះអាចបង្កបាតុភាពមិនល្អផ្សេងៗ ។

ប្រការ១៣.- ការប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវផ្តន្ទាទោសតាមទោសប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ ស្តីពី ការគ្រប់គ្រង លើការប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ។



45

**ប្រការ១៤.-** ខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល-អគ្គាធិការដ្ឋាន-គណៈវិជ្ជាជីវៈនីមួយៗ នៃខេត្តក្រុង-នាយកដ្ឋានមន្ទីរពេទ្យ និង មន្ទីរសុខាភិបាលខេត្ត-ក្រុង មានភារៈកិច្ចត្រួតពិនិត្យតាមដានការអនុវត្តន៍ ប្រកាសនេះ អោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

វេជ្ជ. នុត សុខុម

**កន្លែងទទួល:**

- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា-រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងព័ត៌មាន (ដើម្បីសហការ)
- សាលាក្រុងភ្នំពេញ និង គ្រប់ខេត្តក្រុង
- ក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិ
- ដូចប្រការ ១៤
- ឯកសារ-កាលប្បវត្តិ